MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃ ព្រហស្បតិ៍ ១កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែ មករា ឆ្នាំ២០២៤

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ផែនការបោះផ្សាយលក់មូលបត្ររដ្ឋឆ្នាំ២០២៤

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជូនដំណឹងដល់វិនិយោគិនសក្តានុពលទាំងអស់ ដែលជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានមិនមែនធនាគារនិងហិរញ្ញវត្ថុ ជ្រាបថា អនុលោមតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ និងក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣-២០២៨ របស់រាជរដ្ឋាភិបាល, សម្រាប់ឆ្នាំ ២០២៤ នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងធ្វើការបោះផ្សាយលក់មូលបត្ររដ្ឋ តាមរយៈការដេញថ្លៃនៅលើផ្លែតហ្វម របស់ធនាគារជាតិនៃកម្ពុជា (National Bank of Cambodia Platform – NBCP) ក្នុងទំហំ ៤៤០ 000 000 000 (បួនរយសែសិបប៊ីលាន) រៀល ដូចមានព័ត៌មានលម្អិតខាងក្រោម÷

ក) តម្លៃចារឹកក្នុងមួយប័ណ្ណ÷ ១ 000 000(មួយលាន) រៀល
ខ) ប្រភេទមូលបត្រ÷ ឥណប្រតិទាន ១ឆ្នាំ, ២ឆ្នាំ, ៣ឆ្នាំ, ៥ឆ្នាំ, ១០ឆ្នាំ, និង ១៥ឆ្នាំ
គ) ប្រភេទអត្រាគូប៉ុង÷ ថេរ
ឃ) ការទូទាត់គូប៉ុង÷ រៀងរាល់ ៦ ខែម្តង ដោយគិតចាប់ពីថ្ងៃបោះផ្សាយ
ង) មូលដ្ឋានរាប់ថ្ងៃ÷ Actual/Actual
ច) ការសងប្រាក់ដើម÷ ទូទាត់សងនៅចុងឥណប្រតិទាន
ឆ) វិធីសាស្ត្រដេញថ្លៃ និងចំនួនស្នើដេញថ្លៃ÷ Multiple Price Auction & Multiple Bids
ជ) គម្លាតនៃការបោះផ្សាយ÷ ៤ សប្តាហ៍ម្តង
ឈ) ទំហំគ្រោងបោះផ្សាយ (Indicative Amount)÷

| ប្រភេទមូលបត្រ | ចំនួនដង នៃការបោះផ្សាយ | ទំហំគ្រោងបោះផ្សាយ (ប៊ីលានរៀល) |
|---|---|---|
| ឥណប្រតិទាន ១ឆ្នាំ | ២ | ១២០ - ១៦០ |
| ឥណប្រតិទាន ២ឆ្នាំ | ២ | ១៨០ - ២២០ |
| ឥណប្រតិទាន ៣ឆ្នាំ | ២ | ៨០ - ១០០ |
| ឥណប្រតិទាន ៥ឆ្នាំ | ២ | ២០ - ៤០ |
| ឥណប្រតិទាន ១០ឆ្នាំ | ២ | ២០ - ៤០ |
| ឥណប្រតិទាន ១៥ឆ្នាំ | ២ | ២០ - ៤០ |

៣) កាលវិភាគបោះផ្សាយ÷

| កាលបរិច្ឆេទ | ប្រភេទឥណប្រតិទាន | | | | | |
|---|---|---|---|---|---|---|
| | ១ឆ្នាំ | ២ឆ្នាំ | ៣ឆ្នាំ | ៥ឆ្នាំ | ១០ឆ្នាំ | ១៥ឆ្នាំ |
| ២៤ មករា | √ | | | | | |
| ២១ កុម្ភៈ | | √ | | | | |
| ២០ មីនា | | | √ | | | |
| ២៤ មេសា | √ | | | | | |
| ២៩ ឧសភា | | √ | | | | |
| ២៦ មិថុនា | | | √ | | | |
| ២៤ កក្កដា | | | | √ | | |
| ២១ សីហា | | | | | √ | |
| ១៨ កញ្ញា | | | | | | √ |
| ១៦ តុលា | | | | √ | | |
| ១៣ វិច្ឆិកា | | | | | √ | |
| ១១ ធ្នូ | | | | | | √ |

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងផ្សព្វផ្សាយអំពីយន្តការ និងនីតិវិធីនៃការចូលរួមរបស់គ្រឹះស្ថានមិនមែនធនាគារ និងហិរញ្ញវត្ថុ ក្នុងការវិនិយោគលើមូលបត្ររដ្ឋ នាពេលក្រោយ។ ទន្ទឹមនេះ, សេចក្តីជូនដំណឹងលម្អិតស្តីពីការបោះផ្សាយលក់មូលបត្ររដ្ឋមួយលើកៗ និងលទ្ធផលស្តីពីការដេញថ្លៃមូលបត្ររដ្ឋ នឹងមានផ្សព្វផ្សាយលើបណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា។

*© ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រក្សាសិទ្ធិក្នុងការកែសម្រួលផែនការបោះផ្សាយនេះ តាមការចាំបាច់។*